# ១.រឿង ត្មាតបោកដំរីស

កាលពីព្រេងនាយ មានស្តេចត្មាតមួយ មានពួកពលបរិវារជាច្រើនអាស្រ័យនៅក្នុងព្រៃភ្នំ ។ យប់មួយស្តេចត្មាតនោះ ដេកទៅយល់សប្តយើញថា បានចាប់ស្តេចដំរីស យកមកស៊ីជាអាហារ ។ លុះភ្ញាក់ឡើងក៏ប្រើពួកពល ឲ្យហើរទៅហៅស្តេចដំរីស ។ ពួកសេនាររេហ៍ពលក៏ហើរសំដៅទៅលំនៅនៃស្តេចដំរីសនោះ ដល់ហើយក៏ស្រែកហៅស្តេចដំរីសថា "អឺបងដំរី! ម្ចាស់យើងឲ្យហៅបងដំរីឯងទៅឯលំនៅយើងយ៉ាងឆាប់ ដោយម្ចាស់យើងយល់សប្តថា "បានស៊ីសាច់បងដំរីឯង" ។ ដំរីឮដូច្នោះ ក៏ភ័យញាប់ញ័រឥតឧបមា យំបណ្តើរ លាប្រពន្ធកូននិងពលសេនាបណ្តើរ ដើម្បីទៅតាមពលត្មាតតាមបញ្ជារបស់ស្តេចត្មាត ។ លុះមកដល់កណ្តាលផ្លូវ បានជួបនឹងសុភាទន្សាយ ៗ ក៏សួរទៅស្តេចដំរីថា "យើ ! បងដំរីទៅណាមកណា ក៏រលេះរលាំងថែមទាំងយំសស្រាក់យ៉ាងនេះ ? ដំរីឆ្លើយថា "ឱបងសុភាអើយ ! ស្តេចត្មាតគេយល់សប្តយើញថា គេបានស៊ីសាច់ខ្ញុំឥឡូវនេះខ្ញុំទៅឲ្យគេស៊ីខ្ញុំហើយ " ។ ទន្សាយឆ្លើយថា "យី! បងដំរី រូបប៉ុនបងឯង ម្តេចក៏សុខចិត្តទៅឲ្យអាសត្វត្មាតស៊ីទទេ ៗ យ៉ាងនេះ ចាំខ្ញុំទៅជួយដោះទុកបងឯង ឲ្យរួចរស់បាន" ។ ស្តេចដំរីបានឮទន្សាយថាដូច្នោះមានចិត្តត្រេកអរណាស់ ក៏ហៅទន្សាយឡើងជិះលើខ្នងខ្លួន ដើរសំដៅទៅលំនៅស្តេចត្មាត ។ លុះយើញដំរីមកដល់ហើយ ស្តេចត្មាតញញឹមញញែម រួចនិយាយទៅថា "អឺ ! បងដំរីមកដល់ហើយ យើងត្រូវស៊ីបងឯងក្នុងថ្ងៃនេះ ព្រោះយើងយល់សប្តយើញថា បានស៊ីសាច់បងឯង" ។ នៅពេលដែលដំរីជួបនឹងស្តេចត្មាតនោះទន្សាយធ្វើពុតជាដេកលក់នៅលើខ្នងដំរី ។ ស្តេចត្មាតក៏ស្រែកទៅកាន់ទន្សាយថា "នែ ! បងសុភាមកដេកអីលើខ្នងដំរីដូច្នេះ ? ចុះចេញឲ្យឆាប់យើងនឹងស៊ីដំរីឥឡូវនេះ ។ ទន្សាយឆ្លើយថា " ឈប់ ៗ ! កុំអាលសិន ! បងនិយាយជាមួយដំរីដូចម្តេចខ្លះ អម្បាញ់មិញយើងមិនបានស្តាប់ព្រោះរវល់តែងងុយដេកពេក " ស្តេចត្មាតឆ្លើយថា "យើងយល់សប្តយើញថាស៊ីសាច់ដំរីស" ។ ទន្សាយថា " អឺ ! មែនហើយអម្បាញ់មិញ ខ្ញុំដេកលក់មួយភាំង យល់សប្តថា "បានស្រឡាញ់ប្រពន្ធស្តេចត្មាតឯង" ។ ស្តេចត្មាតឆ្លើយថា "យើ ! បងសុភា ! យើងមិនត្រូវការឲ្យប្រពន្ធយើងទៅបងសុភាឯងទេ" ។ ទន្សាយថា "បើបងឯងមិនឲ្យ ការយល់សប្តរបស់បងត្មាតឯងក៏ឥតបានការអ្វីដែរ ដំរីក៏ខ្ញុំមិនឲ្យបងត្មាតស៊ីដូចគ្នា" ។ ត្មាតក៏ខានបានស៊ីសាច់ដំរី ដោយចាញ់កលឧបាយសុភាទន្សាយ ។ ដំរីសក៏វិលទៅលំនៅខ្លួនវិញទៅ ។ ទន្សាយក៏បោលចូលព្រៃបាត់ដែរ ។